# ច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលគំនិត

ច្បាប់នេះកំណត់អំពីនីតិវិធីនៃការពិន័យស៊ីវិល ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ក្រមនីតិវិធីរដ្ឋប្បវេណី ។

(កំណត់)

ស្តីពីការពិន័យស៊ីវិល មិនត្រឹមតែមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីប៉ុណ្ណោះទេ គឺនៅក្នុងច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និង ក្រមនីតិវិធីរដ្ឋប្បវេណី ក៏មានបញ្ញត្តិដែរ ហេតុដូច្នេះ គួរតែបង្កើតច្បាប់មួយដាច់ដោយឡែកវិញ ។

### មាត្រា ២.- ការអនុវត្តជាសកល

បញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការពិន័យស៊ីវិល លើកលែងតែករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់នេះ ។

(កំណត់)

បញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវអនុវត្តចំពោះចំណុចក្រៅពីចំណុចដែលបានកំណត់នៅក្នុងច្បាប់នេះ លើកលែងតែករណីដែលមាន ភាពផ្ទុយនឹងលក្ខណៈនៃនីតិវិធីនៃការពិន័យស៊ីវិល ។

## ជំពូកទី ២
## សមត្ថកិច្ច

### មាត្រា ៣.- សមត្ថកិច្ច

លើកលែងតែករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង រឿងក្ដីពិន័យស៊ីវិល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលបានកំណត់នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ភាគីនៃនីតិវិធីនៃការពិន័យស៊ីវិល នោះ ។

(កំណត់)

សូមមើលមាត្រា ១៦១ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីដែលមិនមែនជាបណ្ដឹងរបស់ជប៉ុន ។

ឧទាហរណ៍នៃ "ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង" : ករណីដែលរឿងក្ដីលើអង្គសេចក្ដីត្រូវបានចាត់ការនៅក្នុងតុលាការក្រុងភ្នំពេញ ហើយតុលាការក្រុងភ្នំពេញកោះហៅសាក្សីដែលមានលំនៅឋាននៅខេត្តបាត់ដំបង តែសាក្សីនោះមិនបានចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ សាក្សីនោះអាចត្រូវបានពិន័យដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែ "តុលាការ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ មាត្រា ១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះ សំដៅទៅលើតុលាការដែលកំពុងចាត់ការរឿងក្ដីលើអង្គសេចក្ដី ។ ហេតុដូច្នេះ ករណីនេះ គឺជា "ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង" ដែលបានកំណត់នៅក្នុងមាត្រា ៤ នេះ ហើយតុលាការក្រុងភ្នំពេញមានសមត្ថកិច្ចលើការសម្រេចសេចក្ដីអំពីការពិន័យស៊ីវិលចំពោះសាក្សីនោះ ។ ដូចគ្នានេះ ក្នុងករណីដែលភាគីដែលបានស្បថក្លែងបន្លំសេចក្ដីថ្លែងការណ៍ នៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើការសម្រេចសេចក្ដីអំពីការពិន័យស៊ីវិលចំពោះភាគីនោះ មិនមែនជាសាលាដំបូងទេ គឺតុលាការនៃបណ្ដឹងឧទ្ធរណ៍ ដោយយោងតាមកថាខណ្ឌទី ៣ នៃមាត្រា ១៤០ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយបញ្ញត្តិនៃមាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ក្រៅពីនេះ បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងអំពីករណីដែលតតិយជនមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ គឺត្រូវនឹង "ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង" ផងដែរ ។ ជាលទ្ធផល ចំពោះករណីដែលត្រូវពិន័យ ដោយយោងតាមបញ្ញត្តិនៃនីតិវិធីរដ្ឋប្បវេណី តុលាការដែលចាត់ការរឿងក្ដីរដ្ឋប្បវេណីនោះ (រឿងក្ដីលើអង្គសេចក្ដី) មានសមត្ថកិច្ចលើការសម្រេចសេចក្ដីអំពីការពិន័យស៊ីវិល ។

## ជំពូកទី ៣
## នីតិវិធី

### មាត្រា ៤.- ការចាប់ផ្ដើមនីតិវិធី

នីតិវិធីនៃការពិន័យស៊ីវិល ត្រូវចាប់ផ្ដើមដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

មាត្រា ៥.- នីតិវិធីនៃការវិនិច្ឆ័យអំពីការពិន័យស៊ីវិល

១-ការសម្រេចសេចក្ដីអំពីការពិន័យស៊ីវិល ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុ និង សេចក្ដីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើលិខិតដីកាសម្រេចនេះ ។

៣-ដើម្បីចេញដីកាសម្រេចអំពីការពិន័យស៊ីវិល តុលាការត្រូវសួរមតិយោបល់ពីតំណាងអយ្យការ និង ស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគី ជាមុន ។

៤-ចំពោះដីកាសម្រេចអំពីការពិន័យស៊ីវិល តំណាងអយ្យការ និង ភាគីអាចប្ដឹងជំទាស់បាន ។ ដីកាសម្រេចដាក់ពិន័យស៊ីវិល មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

៥-ក្នុងករណីដែលបានចេញដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រាក់ប្រដាប់ក្ដីតុលាការដែលចាំបាច់សម្រាប់នីតិវិធីនៃដីកាសម្រេចអំពីការពិន័យស៊ីវិល រួមទាំងនីតិវិធីនៃការវិនិច្ឆ័យអំពីបណ្ដឹងជំទាស់ គឺជាបន្ទុករបស់បុគ្គលដែលទទួលដីកាសម្រេចនោះ ហើយក្រៅពីករណីនេះគឺជាបន្ទុករបស់រដ្ឋ ។

៦-ក្នុងករណីដែលមានបណ្ដឹងជំទាស់ពីភាគី ចំពោះដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រសិនបើតុលាការនៃបណ្ដឹងជំទាស់ លុបចោលនូវដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មីអំពីការពិន័យស៊ីវិល ទោះបីជាដីកាសម្រេចនេះ ជាដីកាសម្រេចដាក់ពិន័យស៊ីវិលក៏ដោយ ក៏ប្រាក់ប្រដាប់ក្ដីតុលាការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើ នេះ គឺជាបន្ទុករបស់រដ្ឋដែរ ។

(កំណត់)

សូមមើលមាត្រា ១៦២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីដែលមិនមែនជាបណ្ដឹងរបស់ជប៉ុន មាត្រា ២៩ នៃច្បាប់ស្ដីពីការវិនិច្ឆ័យរឿងក្ដីគ្រួសាររបស់ជប៉ុន និង កថាខណ្ឌទី ២ មាត្រា ១ មាត្រា ៣៣ មាត្រា ៣៥ និង មាត្រា ៣៧ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

កថាខណ្ឌទី ១ : កថាខណ្ឌទី ១ មាត្រា ១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចែងខ្លឹមសារដូចគ្នា ហើយតាមលទ្ធផលនៃការអនុវត្តដូចគ្នាជាសកលតាមបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដោយយោងតាមមាត្រា ២ នៃច្បាប់នេះ ហេតុដូច្នេះ យើងអាចគិតថា មិនចាំបាច់ចែងម្តងទៀតនៅក្នុងច្បាប់នេះដែរ ។ ប៉ុន្តែ វិធី និង ប្រភេទនៃការសម្រេចសេចក្តី គឺជាចំណុចសំខាន់មួយ នៅក្នុងនីតិវិធីនៃការពិន័យស៊ីវិល ហេតុនេះហើយបានជាកថាខណ្ឌនេះ ត្រូវបានរៀបចំ ដោយកំណត់ថា ការសម្រេចសេចក្តីអំពីការពិន័យស៊ីវិលត្រូវធ្វើឡើងដោយដីកាសម្រេច ។

កថាខណ្ឌទី ២ : មាត្រា ៣៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចែងខ្លឹមសារដូចគ្នា ។ ប៉ុន្តែ ដូចគ្នាមនឹងកថាខណ្ឌទី ១ ដោយសារចំណុចនេះគឺជាចំណុចសំខាន់មួយ នៅក្នុងនីតិវិធីនៃការពិន័យ កថាខណ្ឌនេះត្រូវបានរៀបចឡើង ។

កថាខណ្ឌទី ៣ : ពាក្យ "ត្រូវស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី" មានន័យថា "ត្រូវរៀបចំឱកាសស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី" ។ នៅក្នុងច្បាប់ជប៉ុន មាននីតិវិធីសង្ខេបដែលអាចចេញដីកាសម្រេចអំពីការពិន័យស៊ីវិល ដោយមិនចាំបាច់ស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី ដែលជាករណីលើកលែងនៃកថាខណ្ឌនេះ ។

កថាខណ្ឌទី ៤ : មាត្រា ៣៥ និង មាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ចែងខ្លឹមសារដូចគ្នា ។ ប៉ុន្តែ ដូចគ្នាមនឹងកថាខណ្ឌទី ១ ដោយសារចំណុចនេះគឺជាចំណុចសំខាន់មួយ នៅក្នុងនីតិវិធីនៃការពិន័យ កថាខណ្ឌនេះ ត្រូវបានរៀបចំឡើង ។

កថាខណ្ឌទី ៥ : ចំពោះ "ក្រៅពីករណីនេះ" គឺមានករណីចេញដីកាសម្រេចមិនពិន័យស៊ីវិល និង ករណីដែលបញ្ចប់នីតិវិធីដោយសារមរណភាពរបស់ភាគី ។

កថាខណ្ឌទី ៦ : ករណីដែល "តុលាការនៃបណ្តឹងជំទាស់ លុបចោលនូវដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មីអំពីការពិន័យស៊ីវិល" គឺជាករណីដែលតុលាការនៃបណ្តឹងជំទាស់បានចេញដីកាសម្រេច "មិនពិន័យស៊ីវិល" និង ករណីដែលតុលាការនៃបណ្តឹងជំទាស់ផ្លាស់ប្តូរចំនួនទឹកប្រាក់ពិន័យស៊ីវិល ។ ក្នុងករណីដែលផ្លាស់ប្តូរទឹកប្រាក់ពិន័យស៊ីវិល មានវិធីឱ្យភាគីទទួលបន្ទុកមួយភាគនៃប្រាក់ប្រដាប់ក្តីតុលាការដែរ តាមសមាមាត្រនៃចំនួនទឹកប្រាក់ពិន័យស៊ីវិលនោះ ប៉ុន្តែ ដើម្បីធ្វើឱ្យនីតិវិធីនេះមានភាពងាយស្រួល ក្នុងករណីដែលមានមូលហេតុលុបចោលនូវដីកាសម្រេចដើម ដូចជាករណីដែលមានមូលហេតុមួយភាគក្នុងបណ្តឹងជំទាស់ ជាអាទិ៍ ក្នុងនេះចែងឱ្យរដ្ឋទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតុលាការទាំងស្រុងតែម្តង ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់បានសម្រេចបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ ត្រូវបកស្រាយថា ត្រូវអនុវត្តកថាខណ្ឌទី៥ មិនមែនកថាខណ្ឌទី៦ទេ (ការបកស្រាយតាមប្រយោគ និង ពាក្យពេចន៍នៃច្បាប់ literal construction) ។ ក្នុងករណីនេះ ទោះបីជាចំនួនទឹកប្រាក់ពិន័យស៊ីវិលត្រូវបានផ្លាស់ប្តូរក៏ដោយ ដោយសារដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវបានសម្រេចដោយតុលាការដែលទទួលនូវការបញ្ជូនត្រឡប់មកវិញ ប្រាក់ប្រដាប់ក្តីតុលាការ រួមទាំងការវិនិច្ឆ័យបណ្តឹងជំទាស់ គឺអាចគិតថា ជាបន្ទុករបស់ភាគី ។ ចំពោះចំណុចនេះ

អាចមានការបកស្រាយផ្សេង ។

## មាត្រា ៦.- ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល

១-ដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវអនុវត្តដោយការបង្គាប់របស់តំណាងអយ្យការ ។ ការបង្គាប់រនេះមានអានុភាពដូចគ្នានឹងលិខិតអនុវត្តដែលមានរូបមន្តអនុវត្ត ។

២-ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវធ្វើដោយអនុលោមតាមគន្ថីទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ប៉ុន្តែ មិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេច មុនពេលអនុវត្តឡើយ ។

៣-ប្រសិនបើយល់ឃើញថាចាំបាច់ ដើម្បីធ្វើការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល តំណាងអយ្យការអាចសួរទៅស្ថាប័នរដ្ឋ ឬ អង្គភាពសាធារណៈ ឬ អង្គភាពឯកជន ឱ្យធ្វើរបាយការណ៍អំពីចំណុចដែលចាំបាច់បាន ។

(កំណត់)

សូមមើលមាត្រា ១៦៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹងរបស់ជប៉ុន និង មាត្រា ២៩ នៃច្បាប់ស្តីពីការវិនិច្ឆ័យរឿងក្តីគ្រួសាររបស់ជប៉ុន ។

កថាខណ្ឌទី ១ : សូមមើលមាត្រា ៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ។

កថាខណ្ឌទី ២ : ការអនុវត្តការពិន័យស៊ីវិលអាចធ្វើតាមនីតិវិធីនៃការអនុវត្តដោយបង្ខំនៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ប៉ុន្តែ (ក្នុងការអនុវត្តជាក់ស្តែង) តាមភាពជាក់ស្តែង ស្តីពីការអនុវត្តគ្រប់ករណី ឬ ការអនុវត្តតែមួយភាគនោះ សូមភាគីកម្ពុជាពិចារណាមើលតាមស្ថានភាពជាក់ស្តែង ។ នៅប្រទេសជប៉ុន តាមស្ថានភាពជាក់ស្តែង ករណីអនុវត្តការពិន័យស៊ីវិលដោយនីតិវិធីនៃការអនុវត្តដោយបង្ខំនោះ មិនសូវមានច្រើនទេ (មានករណីជាច្រើនដែលគេបង់ដោយការដាស់តឿន ហើយមិនទុកដល់ថ្នាក់ឱ្យគេធ្វើការអនុវត្តដោយបង្ខំទេ) ។ នេះគឺដោយសារតែនៅជប៉ុន មានរឿងក្តីពិន័យស៊ីវិលច្រើនមែន តែទឹកប្រាក់ពិន័យស៊ីវិលនោះមិនជាច្រើនប៉ុន្មានទេ ។

កថាខណ្ឌទី ៣ : នេះគឺដើម្បីពិនិត្យមើលទីតាំង ឬ អង្កេតមើលស្ថានភាពទ្រព្យសម្បត្តិរបស់សាមីខ្លួន ។ "ស្ថាប័នរដ្ឋ" មានដូចជា ស្ថាប័នពន្ធដារ (សួរអំពីប្រាក់ចំណូល ឬ ទ្រព្យសម្បត្តិ) ការិយាល័យចុះបញ្ជីអចលនវត្ថុ (បញ្ជាក់អំពីអចលនវត្ថុរបស់សាមីខ្លួន) ជាអាទិ៍ ។ តាមច្បាប់ប្រទេសជប៉ុន គេអាចសួរទៅ "អង្គភាពសាធារណៈ ឬ ឯកជន" ឱ្យធ្វើរបាយការណ៍បាន (សូមមើលកថាខណ្ឌទី៣ មាត្រា ១៦៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹងរបស់ជប៉ុន និង មាត្រា ៥០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌជប៉ុន) ។ "អង្គភាពសាធារណៈ ឬ ឯកជន" គឺជាអង្គភាព

សាធារណៈ ឬ ឯកជន ក្នុងន័យទូលំទូលាយ ដោយមិនគិតថា មាននីតិបុគ្គលភាព ឬអត់ទេ ហើយមានរួមទាំង "សាលារៀន សភាពាណិជ្ជកម្មនិងឧស្សាហកម្ម ផ្សារភាគហ៊ុន និង អង្គភាពផ្សេងទៀត" ដែលបានកំណត់នៅក្នុងមាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ព្រមទាំងស្ថាប័នហិរញ្ញវត្ថុ មន្ទីរពេទ្យ ក្រុមហ៊ុនទូរស័ព្ទ ជាដើម ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

### មាត្រា ៧.- កាលបរិច្ឆេទនៃការអនុវត្ត

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។